KHMER

Putting Children First NCAC

ការធានាទៅលើគុណភាពមើលថែរក្សាគ្រួសារនៅពេលថ្ងៃ

**Family Day Care Quality Assurance**

# Handbook

# សៀវភៅប្រើ



Second Edition 2004

National Childcare Accreditation Council

© រដ្ឋាភិបាលអូស្រ្តាលី  ឆ្នាំ២០០៤

ISBN 0-9750664-4-7

កិច្ចការដែលចុះនៅក្នុងសៀវភៅនេះត្រូវបានរក្សាសិទ្ធិ។  ផ្សេងពីការយកទៅប្រើណាមួយដូចបានអនុញ្ញាត នៅ ក្រោម *Copyright Act* 1968  (ច្បាប់រក្សាសិទ្ធិ  ឆ្នាំ១៩៦៨)  និង/ឬសំរាប់គោលបំណងដូចបានគ្រោងទុកដោយអ្នកបោះពុម្ពផ្សាយ ត្រូវបានហាមមិនឲ្យយកផ្នែកណាមួយទៅបោះពុម្ពឡើងវិញ  ដោយវិធីណាមួយ  ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍ អក្សរពី  National Childcare Accreditation Council  ឡើយ។

រៀបចំឡើងដោយ National Childcare Accreditation Council Inc.។

បោះពុម្ពដោយ the National Childcare Accreditation Council Inc., Level 3, 418a Elizabeth Street, Surry Hills NSW 2010, Australia (www.ncac.gov.au)។

# សេចក្តីណែនាំ

ការធានាទៅលើគុណភាពមើលថែរក្សាគ្រួសារនៅពេលថ្ងៃ (Family Day Care Quality Assurance) (FDCQA) ផ្តួចផ្តើមឡើងដើម្បីផ្តល់ទៅដល់កុមារនៅក្នុងកន្លែងមើលថែរក្សាគ្រួសារនៅពេលថ្ងៃពេញទូទាំងប្រទេសអូស្ត្រាលី នូវការមើលថែរក្សាដែលមានគុណភាពខ្ពស់ដែលផ្សព្វផ្សាយនូវការរៀនសូត្រ និងការធំលូតលាស់របស់គេឲ្យបានល្អប្រសើរក្នុងវ័យដំបូងដ៏សំខាន់បំផុត។ គោលដៅដ៏ធំទូលាយនៃ FDCQA គឺធ្វើឲ្យបានច្បាស់ប្រាកដថាកុមារនៅកន្លែងមើលថែរក្សាពេញមួយថ្ងៃបានទទួលការបណ្តុះបណ្តាល និងការពិសោធន៍ល្អ ព្រមទាំងការប្រាស្រ័យទាក់ទងនឹងគ្នា ដែលជួយផ្គត់ផ្គង់គ្រប់ទាំងចំណុចនៃការធំលូតលាស់របស់គេ។ ការនេះអាចធ្វើដូច្នោះបានដោយសារការកំណត់ន័យយ៉ាងច្បាស់លាស់លើការមើលថែរក្សាគ្រួសារនៅពេលថ្ងៃដែលមានគុណភាព ហើយផ្តល់នូវវិធីមួយដើម្បីវាស់ស្ទង់គុណភាពនៃការមើលថែរក្សាដែលផ្តល់ដោយគ្រោងការណ៍ និងដើម្បីសម្គាល់ទៅលើផ្នែកទាំងឡាយដើម្បីកែលំអគុណភាពជាបន្តបន្ទាប់។

FDCQA គឺជាការផ្តួចផ្តើមរបស់រដ្ឋាភិបាលអូស្ត្រាលី តភ្ជាប់ទៅនឹងប្រាក់បំណាច់មើលថែទាំកុមារ (Child Care Benefit) និងជំនួយលើការអនុវត្ត (Operational Assistance) ដែលបានយល់ព្រមសំរាប់គ្រោងការណ៍មើលថែរក្សាគ្រួសារនៅពេលថ្ងៃ។[1] ចាប់តាំងពីបានកកើតឡើងនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០១ FDCQA ត្រូវបានមើលគ្រប់គ្រងដោយ National Childcare Accreditation Council Inc (NCAC)។

ថ្វីដ្បិតតែមានប្រព័ន្ធទទួលស្គាល់ជាផ្លូវការដោយស្ម័គ្រពីចិត្ត សំរាប់កិច្ចបំរើមើលថែរក្សាកុមារនៅតាមប្រទេសឯទៀតជាយ៉ាងណាក្តី FDCQA នៃប្រទេសអូស្ត្រាលី គឺមានតែមួយគត់នៅក្នុងកំរិតអន្តរជាតិ ដោយព្រោះថាវាជាកម្មវិធីធានារ៉ាប់រងលើគុណភាពទីមួយ សំរាប់កិច្ចបំរើមើលថែរក្សាគ្រួសារនៅពេលថ្ងៃនៅក្នុងពិភពលោក ដែលត្រូវបានតភ្ជាប់ទៅនឹងថវិកាផ្គត់ផ្គង់លើការមើលថែរក្សាកុមារតាមរយៈច្បាប់ ហើយជាកិច្ចបំរើដែលបានទទួលថវិកាផ្គត់ផ្គង់ និងគាំទ្រពីរដ្ឋាភិបាលសហព័ន្ធ។ ប្រព័ន្ធធានាទៅលើគុណភាពដែលមានជោគជ័យ ក៏អនុវត្តនៅតាមមណ្ឌលមើលថែរក្សាក្នុងរយៈពេលវែងនៅពេលថ្ងៃ និងកិច្ចបំរើមើលថែរក្សាក្រៅម៉ោងសាលាផងដែរ។[2] ការកែប្រែនៃ FDCQA សំរាប់ការមើលថែរក្សាគ្រួសារនៅពេលថ្ងៃនឹងត្រូវពង្រីកចំនួននៃពត៌មានដែលមានផ្តល់ជូនសំរាប់គ្រួសារ ក្នុងកាលដែលគេធ្វើជម្រើសលើការមើលថែរក្សាសំរាប់កូនរបស់ខ្លួន។

FDCQA គឺពឹងផ្អែកទៅលើអ្វីដែលនៅក្នុងពេលបច្ចុប្បន្ននេះ ត្រូវបានគេទទួលស្គាល់អំពីការអនុវត្តគុណភាពមើលថែរក្សាកុមារ ពីការស្រាវជ្រាវ និងការពិសោធន៍ និងពីការពិគ្រោះដែលមានទំហំធំធេងពេញទូទាំងកន្លែងមើលថែរក្សាគ្រួសារនៅពេលថ្ងៃ និងពីរង្វង់វ័យកុមារភាព។ *សៀវភៅណែនាំលើការអនុវត្តគុណភាព* FDCQA (*FDCQA Quality Practices Guide*) គូសបញ្ជាក់ប្រាប់អំពីកន្លែងគុណភាពទាំង៦ និងគោលការណ៍ទាំង៣០នៃគុណភាពមើលថែរក្សា។ វាក៏ដាក់បញ្ចូលសញ្ញាបង្ហាញឲ្យដឹងមុនលើគុណភាពដែលត្រូវបានគ្រោងឡើង ដើម្បីជួយណែនាំការអនុវត្តនៃគ្រោងការណ៍មើលថែរក្សាគ្រួសារនៅពេលថ្ងៃផងដែរ។

---

[1] សំរាប់គោលបំណងនៃ FDCQA ពាក្យ 'គ្រោងការណ៍' រាប់បញ្ចូលទាំងអ្នកមើលថែរក្សា បុគ្គលិកក្រុមសម្របសម្រួលចាត់ចែង និងអ្នកមើលគ្រប់គ្រង។

[2] ការធានាទៅលើគុណភាពមើលថែរក្សាក្រៅម៉ោងសាលា (Outside School Hours Care Quality Assurance) (OSHCQA) សំរាប់កិច្ចបំរើមើលថែរក្សាក្រៅម៉ោងសាលា និងប្រព័ន្ធកែលំអគុណភាព និងប្រព័ន្ធទទួលស្គាល់ជាផ្លូវការ (Quality Improvement and Accreditation System) (QIAS) សំរាប់មណ្ឌលមើលថែរក្សាក្នុងរយៈពេលវែង។

## តើអ្វីទៅ ការមើលថែរក្សាកុមារដែលមានគុណភាព?

កិច្ចបំរើ*មើលថែរក្សា*កុមារដែលមានគុណភាព ផ្តល់ច្រើនលើសជាងការគ្រាន់តែមើលថែរក្សាកុមារ - ការមើលថែរក្សាគ្រួសារនៅពេលថ្ងៃដែលមានគុណភាពជួយអប់រំ និងពង្រីកនូវទំនាក់ទំនងជាក់លាក់រវាងអ្នកមើលថែរក្សា និងកុមារ និងគ្រួសាររបស់ខ្លួន។ វាផ្តល់នូវការពិសោធន៍សំរាប់កុមារដោយពង្រីកការចេះគិត និងភាសា ជួយគេឲ្យរៀនចេះដឹង និងចំរើនធំធាត់។

## គ្រោងការណ៍មើលថែរក្សាគ្រួសារនៅពេលថ្ងៃដែលមានគុណភាពល្អ (scheme):

- មានទស្សនៈ និងគោលដៅច្បាស់លាស់ មានការព្រមព្រៀងគ្នារវាងអ្នកមើលថែរក្សា បុគ្គលិក និងគ្រួសារដែលដឹកនាំគ្រប់ទាំងសកម្មភាពរបស់គ្រោងការណ៍។
- ទទួលស្គាល់ គោរព និងផ្គត់ផ្គង់ទៅដល់ភាពផ្ទាល់ៗខ្លួន និងភាពឯករាជនៃកុមារទាំងអស់ រាប់បញ្ចូលទាំងកុមារមកពីសាវតាផ្សេងៗ និងកុមារដែលមានសេចក្តីត្រូវការបន្ថែមទៀត។
- ចេះគិតពិចារណាលើភាពសមរម្យនៃអស់ទាំងការពិសោធន៍ និងសកម្មភាពទាំងឡាយ ដែលប៉ះពាល់ដល់កុមារក្នុងទំនាក់ទំនងទៅនឹងការចំរើនធំធាត់របស់គេ ហើយ
- លើកទឹកចិត្តគ្រួសារឲ្យទាក់ទិននៅក្នុងគ្រោងការណ៍ ហើយផ្គត់ផ្គង់ទំនាក់ទំនងរវាងអ្នកមើលថែរក្សា បុគ្គលិក និងគ្រួសារដើម្បីឲ្យគេអាចគាំទ្រគ្នាទៅវិញទៅមកក្នុងមុខការបំពេញរបស់គេ។

ការមើលថែរក្សាដែលមានគុណភាព គិតទៅលើមូលដ្ឋាននៃការដឹងយល់ច្បាស់លាស់អំពីវ័យកុមារភាព រាប់បញ្ចូលទាំងរបៀបកុមាររៀនចេះ និងចំរើនធំធាត់។ អ្នកមើលថែរក្សាដែលផ្តល់នូវកម្រិតនៃការមើលថែរក្សាល្អប្រសើរ នឹងដឹងអំពីអ្វីជាការពិសោធន៍ល្អសមរម្យសំរាប់កុមារដែលមានអាយុខុសៗគ្នា ហើយមានការដឹងយល់ទៅដល់កុមារម្នាក់ៗ ព្រមទាំងទំហំនៃការចំរើនធំធាត់ និងផ្នែកវប្បធម៌ផងដែរ។ អ្នកមើលថែរក្សាទាំងនេះក៏ដឹងអំពីរបៀបទាក់ទង ហើយចងភ្ជាប់នូវទំនាក់ទំនងល្អជាមួយកុមារផងដែរ។ គេនឹងរៀបចំឲ្យមានបរិយាកាសមួយដែលមានភាពលំនឹងនៃការបណ្តុះបណ្តាលដែលបានគ្រោងទុក និងការពិសោធន៍ដែលប្រកបដោយឆន្ទះ និងលំនឹងនៃរយៈពេលសកម្មប្រកបទៅ ដោយការសំរាកសមរម្យ ស្របទៅនឹង ការ ចូលចិត្ត និងសេចក្តីត្រូវការរបស់កុមារម្នាក់ៗផ្ទាល់។

ការកែលំអលើគុណភាព គឺជាដំណើរការចាត់ចែងរួមគ្នា ដែលទាក់ទិនអស់ទាំងសមាជិកនៃគ្រោងការណ៍។ FDCQA លើកទឹកចិត្តគ្រោងការណ៍នីមួយៗ និងគ្រួសាររបស់ខ្លួនឲ្យធ្វើការរួមគ្នាក្នុងមុខការបំពេញរបស់គេ ក្នុងការផ្តល់អត្ថន័យទៅលើទស្សនៈ និងគោលដៅដើម្បីណែនាំការពិសោធន៍សមរម្យសំរាប់កុមារ បែបនៃការធ្វើការជួយគ្នាទៅវិញទៅមក និងគ្រប់ទាំងសកម្មភាពឯទៀតរបស់គ្រោងការណ៍។

គ្រោងការណ៍មើលថែរក្សាគ្រួសារនៅពេលថ្ងៃទាំងអស់ ដែលចុះឈ្មោះជាមួយ NCAC ដើម្បីចូលរួមនៅក្នុង FDCQA ត្រូវបានតម្រូវឲ្យរៀបចំដំណើរការចាត់ចែងទាំងឡាយ ដើម្បីកែលំអគុណភាពជាបន្តបន្ទាប់។ ថ្វីដ្បិតតែគ្រោងការណ៍នីមួយៗអាចកំណត់អំពីរបៀបដែលការនេះអាចសំរេចគោលបំណង ក្នុងភាពប្រសើរសំរាប់ខ្លួនជាយ៉ាងណាក្តី FDCQA តម្រូវដល់គ្រោងការណ៍ដែលត្រូវបង្ហាញឲ្យឃើញថា:

(ក) គេមានដំណើរការចាត់ចែងកែលំអគុណភាពជាបន្តបន្ទាប់ ហើយ

(ខ) ដំណើរការចាត់ចែងទាំងនេះ ត្រូវបានប្រតិបត្តិតាមដោយធ្វើការសិក្សាដោយខ្លួនឯងជាទៀងទាត់ដូចបានគូសបញ្ជាក់ប្រាប់នៅក្នុង*សៀវភៅណែនាំអនុវត្តលើគុណភាព FDCQA (FDCQA Quality Practices Guide)* (2004) ។

## មូលហេតុគុណភាពមានសារៈសំខាន់ នៅក្នុងការមើលថែរក្សាកុមារក្នុង

រយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ចំនួនកុមារចាប់ពីកំណើតទៅទល់នឹងឆ្នាំចូលរៀនសាលាបឋមសិក្សា ដែលបានទទួលការមើលថែរក្សាក្រៅផ្ទះរបស់ខ្លួនគឺកើនចំនួនយ៉ាងច្រើនដោយមានការរីកចំនួនគ្រួសារដែលឪពុកម្តាយទាំងពីរធ្វើការ ឬក្នុងករណីនៃឪពុក ឬម្តាយតែម្នាក់ដែលមានតែឪពុក ឬម្តាយម្នាក់ធ្វើការ។ ការប្រែប្រួល និងសេចក្តីត្រូវការផ្នែកៗនៃគ្រួសារនៅក្នុងប្រទេសអូស្ត្រាលីដែលរាប់បញ្ចូលទាំងការមើលថែរក្សាទាក់ទិននឹងការងារ ឬមិនទាក់ទិននឹងការងារត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសេចក្តីត្រូវការ ដែលមានកាន់តែច្រើនឡើងសំរាប់កិច្ចបំរើមើលថែរក្សាកុមារ។ ចំនួនពេលមធ្យមដែលកុមារម្នាក់ៗចំណាយនៅក្នុងការមើលថែរក្សា គឺរីកចំនួនយ៉ាងច្រើន។ កុមារយ៉ាងតូចៗអាចចំណាយពេលដល់ទៅ១២៥០០ម៉ោងនៅកន្លែងមើលថែរក្សា មុនពេលចាប់ផ្តើមចូលរៀន នេះគឺមានចំនួនតែ៥០០ម៉ោងប៉ុណ្ណោះ តិចជាងកុមារដែលចំណាយពេលនៅក្នុងមេរៀនក្នុងអម្លុងពេល១៣ឆ្នាំនៃការរៀនសូត្រ។[3]

គុណភាពនៃការមើលថែរក្សាដែលកុមារតូចៗទទួល ការពិសោធន៍លើការរៀនសូត្ររបស់គេ និងទំនាក់ទំនងជាពិសេសនៅក្នុងរយៈពេលពីរ ឬបីឆ្នាំដំបូងនៃការរស់នៅរបស់គេ គឺមានសារៈសំខាន់ជាទីបំផុតក្នុងការសួនប៉ាន់អនាគតរបស់គេ។ នេះត្រូវបានគេទទួលស្គាល់យ៉ាងធំទូលាយថា យើងរៀនសូត្របានច្រើននៅក្នុងរយៈពេលប្រាំឆ្នាំដំបូងនៃការរស់នៅរបស់យើង ជាងអម្លុងពេល៥ឆ្នាំណាទៀត។ ការស្រាវជ្រាវលើការចំរើនធំធាត់នៃខួរក្បាលបានបង្ហាញប្រាប់ថាការពិសោធន៍ល្អនៅដើមដំបូងនៃការរស់នៅ ដូចមានផ្តល់នៅតាមកន្លែងមើលថែរក្សាកុមារដែលមានគុណភាពខ្ពស់ ជួយផ្គត់ផ្គង់ទៅដល់ការចំរើនធំធាត់របស់កុមារ។ កិច្ចបំរើមើលថែរក្សាកុមារដែលមានគុណភាព ដើរតួរយ៉ាងសំខាន់ក្នុងការលើកស្ទួយការរៀនសូត្រឲ្យបានល្អប្រសើរឡើង និងការសំរេចជោគជ័យពេញក្នុងឆាកជីវិតរបស់គេ ក្នុងការផ្តល់នូវឱកាសល្អច្រើនឡើងពេញមួយជីវិតនិងលទ្ធផល និងការកាត់បន្ថយនូវសុខភាពមិនល្អ នៅក្នុងការរស់នៅសំរាប់ពេលក្រោយៗមក។

ការចំរើនលូតលាស់នៃការចេះដឹងរបស់យើងអំពីកុមារតូចៗ ការប្រែប្រួល និងសេចក្តីត្រូវការផ្នែកៗនៃគ្រួសារ ចំនួនកុមារនៅក្រោមការមើលថែរក្សា និងចំនួនពេលម៉ោងដែលគេចំណាយនៅកន្លែងមើលថែរក្សា គូសបញ្ជាក់ប្រាប់អំពីសារៈសំខាន់នៃ FDCQA ក្នុងការផ្តល់នូវគុណភាពខ្ពស់នៃការមើលថែរក្សាសំរាប់កុមារនៅគ្រោងការណ៍មើលថែរក្សាគ្រួសារនៅពេលថ្ងៃពេញទាំងប្រទេសអូស្ត្រាលី។

[3] ការមើលថែរក្សាកុមារ: ៥០(អាទិត្យ) x ៥០(ម៉ោង) x ៥(ឆ្នាំ)=១២៥០០ម៉ោង ការរៀនសូត្រ: ៤០(អាទិត្យ) x ២៥(ម៉ោង) x ១៣(ឆ្នាំ)=១៣០០០ម៉ោង

ថ្មីដ្បិតតែការមើលថែរក្សាគ្រួសារនៅពេលថ្ងៃ ត្រូវបានទទួលស្គាល់រួចជាស្រេចថាបានផ្តល់ទៅដល់កុមារនូវការមើលថែរក្សាដែលមានគុណភាពជាយ៉ាងណាក្តី ប្រព័ន្ធ FDCQA ផ្តល់ឡើងដើម្បីឲ្យការមើលថែរក្សានេះត្រូវបានទទួលដឹងឮ ដោយដំណើរទទួលស្គាល់ជាផ្លូវការ។ គោលដៅសំខាន់បំផុតនៃប្រព័ន្ធ FDCQA គឺដើម្បីផ្សព្វផ្សាយនូវ និងឲ្យបានច្បាស់ប្រាកដទៅលើលទ្ធផលនៃគុណភាពសំរាប់កុមារចំនួន៩៣៤៥០នាក់ នៅកន្លែងមើលថែរក្សាគ្រួសារនៅពេលថ្ងៃក្នុងប្រទេសអូស្ត្រាលី។[4]

### ការបង្កើតឲ្យមាន ការធានាទៅលើគុណភាពមើលថែរក្សាគ្រួសារនៅពេលថ្ងៃ (Family Day Care Quality Assurance)

NCAC ចាប់ផ្តើមទទួលខុសត្រូវចំពោះការចាត់ចែងនៃការបង្កើតឲ្យមានការធានាទៅលើគុណភាពមើលថែរក្សាគ្រួសារនៅពេលថ្ងៃ (Family Day Care Quality Assurance) នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០១។ ទោះបីជាយ៉ាងណាក្តី ការបង្កើតឲ្យមាន FDCQA ត្រូវបានលើកយកមកពិនិត្យមើលនៅក្នុងសហគមន៍មើលថែរក្សាគ្រួសារអូស្ត្រាលីនៅពេលថ្ងៃ គឺកើតមានចាប់តាំងពីពាក់កណ្តាលនៃគ្រាឆ្នាំ១៩៩០មម្លេះ។

នៅមុនការបោះឆ្នោតរបស់ខ្លួនលើច្បាប់ *ភាពច្បាស់លាស់សំរាប់គ្រួសារ (Certainty for Families)* នៃខែកុម្ភៈ ឆ្នាំ១៩៩៦ រដ្ឋាភិបាលអូស្ត្រាលីបានប្រកាសអំពីការប្តូរផ្តេចរបស់ខ្លួន លើការធានាគុណភាពនៅក្នុងការមើលថែរក្សាគ្រួសារនៅពេលថ្ងៃ។ ចាប់ពីការប្តូរផ្តេចនេះមកចំនួនកិច្ចការយ៉ាងច្រើនដែលបានរៀបចំទុកត្រូវបានអនុវត្តឡើង។ នៅក្នុងអម្លុងពេលនេះ កិច្ចការក៏ត្រូវបានរៀបចំឡើងចំពោះការចេញច្បាប់នៃការមើលថែរក្សាគ្រួសារនៅពេលថ្ងៃ ដោយរដ្ឋាភិបាលប្រចាំរដ្ឋ និងដែនដី។ ព្រឹត្តិការណ៍សំខាន់ៗនៅក្នុងការបង្កើតឲ្យមាន FDCQA រាប់បញ្ចូលទាំងការបង្កើតខ្នាតគំរូជាតិសំរាប់ការមើលថែរក្សាគ្រួសារនៅពេលថ្ងៃក្នុងឆ្នាំ១៩៩៧ និងការរៀបចំនៅក្នុងឆ្នាំ១៩៩៨ នៃក្រុមបំពេញកិច្ចការមើលថែរក្សាគ្រួសារនៅពេលថ្ងៃ លើការធានាទៅលើគុណភាព ដែលទទួលខុសត្រូវចំពោះការបង្កើតឲ្យមាននូវគំរូការធានាទៅលើគុណភាព សំរាប់ការមើលថែរក្សាគ្រួសារនៅពេលថ្ងៃ។

ក្នុងអម្លុងឆ្នាំ២០០០ និង២០០១ គំរូនៃគ្រឿងឧបករណ៍ប៉ាន់ស្មង់ដោយខ្លួនឯងដើម្បីគាំទ្រប្រព័ន្ធធានាទៅលើគុណភាព ត្រូវបានបង្កើតឲ្យមានឡើង។ គ្រោងការណ៍មើលថែរក្សាគ្រួសារនៅពេលថ្ងៃចំនួន១១ ពេញទូទាំងប្រទេសអូស្ត្រាលី គឺជាផ្នែកនៃកម្មវិធីសាកល្បងសំរាប់រយៈពេល៦ខែនៃគំរូ និងគ្រឿងឧបករណ៍ប្រព័ន្ធធានាទៅលើគុណភាព ដែលត្រូវបានដាក់ស្នើសុំ។ កម្មវិធីសាកល្បងត្រូវបានតំណាងដោយរដ្ឋនីមួយៗ និងដែនដី ដើម្បីឲ្យបានច្បាស់ប្រាកដទៅលើភាពដូចគ្នា និងភាពផ្សេងគ្នានៃការមើលថែរក្សាគ្រួសារនៅពេលថ្ងៃ ត្រូវបានដាក់ជាតំណាង។

ការប្រជុំពិគ្រោះដែលមានតៗគ្នាពេញទូទាំងប្រទេសអូស្ត្រាលី រៀបចំឡើងដោយក្រសួងរដ្ឋាភិបាលអូស្ត្រាលីនៃកិច្ចបំរើគ្រួសារ និងសហគមន៍ ត្រូវបានប្រព្រឹត្តឡើងនៅក្នុងខែឧសភា ឆ្នាំ២០០១ ដើម្បីជម្រាបប្រាប់វង្វង់កិច្ចបំរើមើលថែរក្សាគ្រួសារនៅពេលថ្ងៃ អំពីប្រព័ន្ធធានាទៅលើគុណភាពដែលត្រូវបានដាក់ស្នើសុំនេះ និងដើម្បីស្វែងរកការផ្តល់យោបល់ត្រឡប់មកវិញអំពីប្រព័ន្ធនេះ។

ចាប់តាំងពីការអនុវត្តនៃ FDCQA នៅក្នុងខែកក្កដាឆ្នាំ២០០១មក NCAC តែងស្វែងរកយ៉ាងសកម្មដើម្បីពិនិត្យមើលឡើងវិញនៃសហគមន៍មើលថែរក្សាគ្រួសារនៅពេលថ្ងៃ អំពីគ្រប់ទាំងចំណុចសំខាន់ៗរបស់ប្រព័ន្ធ។

យោបល់ឆ្លើយតបដែលបានទទួលមកវិញ ផ្តល់ដោយសហគមន៍មើលថែរក្សាគ្រួសារនៅពេលថ្ងៃ រួមចំណែកយ៉ាងច្រើនទៅដល់ដំណើរនៃការពិនិត្យមើលឡើងវិញលើសៀវភៅណែនាំ FDCQA *Quality Practices Guide* (1st edition, 2001)។

នៅក្នុងការពិគ្រោះជាមួយនឹងក្រុមប្រឹក្សាជាតិមើលថែរក្សាគ្រួសារនៅពេលថ្ងៃនៃអូស្ត្រាលី (National Family Day Care Council of Australia) (NFDCCA), NCAC បានបង្កើតឲ្យមានក្រុមស្វែងរកយោបល់នៃអ្នកផ្តល់កិច្ចបំរើមើលថែរក្សាគ្រួសារនៅពេលថ្ងៃ ដើម្បីធ្វើការជាមួយបុគ្គលិក NCAC ទៅលើការកែសម្រួលបោះពុម្ពលើកទី១នៃសៀវភៅណែនាំនេះ។

NCAC សូមថ្លែងអំណរគុណដល់ NFDCCA និងក្រុមស្វែងរកយោបល់ចំពោះការជួយជ្រោមជ្រែងរបស់គេ ដើម្បីសម្របសម្រួលការផលិតនៃសៀវភៅណែនាំ FDCQA *Quality Practices Guide* (2nd edition, 2004)។ NCAC មានទំនុកទុកចិត្តថា គ្រោងការណ៍មើលថែរក្សាគ្រួសារនៅពេលថ្ងៃនឹងយល់ឃើញថាការកែសម្រួលលើកទី២ មានការកែលំអពីលើការកែ សម្រួល ពីលើកមុនៗ ហើយវាបង្ហាញឲ្យឃើញការរីកចំរើនដែលគ្រោងការណ៍បានធ្វើក្នុងរយៈពេលខ្លីប៉ុន្មានឆ្នាំនេះ។

ដើម្បីទទួលយកពត៌មានស្តីអំពីការបង្កើតនៃ FDCQA សូមយោងទៅសេចក្តីបន្ថែមដែលមាននៅចុងសៀវភៅ FDCQA *Quality Practices Guide* (2004)។

### ការបោះពុម្ពផ្សាយរបស់ FDCQA

សៀវភៅ *FDCQA Handbook* (2004) ផ្តល់នូវការមើលឃើញដោយសង្ខេបនៃ FDCQA ហើយគឺជាការចុះផ្សាយដៃគូគ្នានឹងសៀវភៅ FDCQA *Quality Practices Guide* (2004) និង FDCQA *Self-study Report* (2004)។ សៀវភៅទាំងនេះមានត្រូវបានគ្រោងឡើងដើម្បីជួយណែនាំ និងជួយគ្រោងការណ៍ក្នុងការកែលំអគុណភាព នៅក្នុងការអនុវត្តមើលថែរក្សា និងដើម្បីបំពេញទៅលើសេចក្តីតម្រូវដើម្បីបំពេញរបាយការណ៍នៃ FDCQA។ សៀវភៅទាំងនេះមានផ្តត់ផ្តង់ដំបូងសំរាប់គ្រោងការណ៍មើលថែរក្សាគ្រួសារនៅពេលថ្ងៃ ដែល បានចុះឈ្មោះ ស្របច្បាប់ដើម្បីចូលរួមនៅក្នុង FDCQA។ សៀវភៅទាំងនេះអាចទិញបានបន្ថែមពី NCAC ហើយអាចទទួលយកបានដោយឥតគិតថ្លៃ ដោយចម្លងយកពីគេហទំព័ររបស់ NCAC (www.ncac.gov.au)។

[4] ការស្រង់ចំនួននៃកិច្ចបំរើមើលថែរក្សាកុមារ ក្រសួងកិច្ចបំរើគ្រួសារ និងសហគមន៍។

# កន្លែងគុណភាពទាំង៦ និងគោលការណ៍ទាំង៣០

## កន្លែងគុណភាពទី 1 – ការប្រាស្រ័យទាក់ទងនឹងគ្នា

គោលការណ៍ទី 1.1: អ្នកមើលថែរក្សា និងបុគ្គលិកក្រុមសម្របសម្រួលចាត់ចែងប្រាស្រ័យទាក់ទងជាមួយគ្រប់ទាំងកុមារ ក្នុងលំនាំដែលកក់ក្តៅ មិត្តភាព ហើយប្រកបដោយការគោរព។

គោលការណ៍ទី 1.2: ការធ្វើទំនាក់ទំនងរវាងបុគ្គលិកក្រុមសម្របសម្រួលចាត់ចែង និងគ្រួសារមានប្រសិទ្ធិភាព ហើយគាំទ្រទីកន្លែងរបស់កុមារនៅក្នុងការមើលថែរក្សា។

គោលការណ៍ទី 1.3: ការធ្វើទំនាក់ទំនងរវាងអ្នកមើលថែរក្សា និងគ្រួសារមានប្រសិទ្ធិភាព ហើយគាំទ្រដល់គ្រួសារ និងកុមារឲ្យបានជាប់នៅក្នុងការមើលថែរក្សា។

គោលការណ៍ទី 1.4: ការរៀបចំផ្ទាល់ខ្លួន និងគ្រួសារនៃអ្នកមើលថែរក្សាផ្តល់នូវបរិយាការក្នុងផ្ទះប្រកបដោយវិជ្ជមាន ដែលគាំទ្រការផ្គត់ផ្គង់មើលថែរក្សាគ្រួសារនៅពេលថ្ងៃ។

គោលការណ៍ទី 1.5: ទំនាក់ទំនងមាននៅក្នុងគ្រោងការណ៍ឲ្យតម្លៃភាពផ្សេងៗពីគ្នា ការរួមដៃគ្នាធ្វើការ ការគោរពចំពោះគ្នាទៅវិញទៅមក ការយល់ដឹង និងវិជ្ជាជីវៈនិយម។

## កន្លែងគុណភាពទី 2 – បរិយាការដែលមើលឃើញនៅជុំវិញ

គោលការណ៍ទី 2.1: ទីកន្លែងខាងក្នុង និងខាងក្រៅនៃផ្ទះរបស់អ្នកមើលថែរក្សា និងកន្លែងលេងជុំគ្នា* ស្ថិតនៅក្នុងបរិយាការជាទីកក់ក្តៅ សុខស្រួល ហើយរាក់ទាក់សំរាប់កុមារ។

គោលការណ៍ទី 2.2: កុមារទាំងអស់មានលទ្ធភាពនឹងប្រើប្រាស់គ្រឿងសម្ភារៈ និងគ្រឿងប្រដាប់ផ្សេកៗដែលជាទីចាប់ចិត្ត។

គោលការណ៍ទី 2.3: គ្រឿងប្រដាប់ប្រើដោយក្រុមសម្របសម្រួលចាត់ចែង ជាទីស្វាគមន៍ឲ្យប្រើ ហើយអាចប្រើប្រាស់បាន។

## កន្លែងគុណភាពទី 3 – ការពិសោធន៍ ការរៀនសូត្រ និងការចំរើនលូតលាស់របស់កុមារ

គោលការណ៍ទី 3.1: អ្នកមើលថែរក្សាឆ្លើយតបទៅនឹងការចូលចិត្ត និងសមត្ថភាពនៃគ្រប់ទាំងកុមារក្នុងលំនាំដែលគាំទ្រការរៀនសូត្រនៅក្នុងបរិយាការតាមផ្ទះ។

គោលការណ៍ទី 3.2: បុគ្គលិកក្រុមសម្របសម្រួលចាត់ចែងគាំទ្រការរៀនសូត្ររបស់កុមារ តាមរយៈការទៅសួរសុខទុក្ខតាមផ្ទះ និង/ឬពេលលេងជុំគ្នា។

គោលការណ៍ទី 3.3: អ្នកមើលថែរក្សា និងបុគ្គលិកក្រុមសម្របសម្រួលចាត់ចែងណែនាំចរិយាមារយាទរបស់កុមារក្នុងលំនាំជាវិជ្ជមាន។

គោលការណ៍ទី 3.4: អ្នកមើលថែរក្សា និងបុគ្គលិកក្រុមសម្របសម្រួលចាត់ចែងជម្រុញលើកទឹកចិត្តការឲ្យមានការត្រឡប់មកភាពដើមវិញ និងសមត្ថភាពផ្នែកសង្គមនៅក្នុងគ្រប់ទាំងកុមារ។

គោលការណ៍ទី 3.5: អ្នកមើលថែរក្សា និងបុគ្គលិកក្រុមសម្របសម្រួលចាត់ចែងជម្រុញលើកទឹកចិត្តសមត្ថភាពផ្នែករូបកាយ នៅក្នុងគ្រប់ទាំងកុមារ។

គោលការណ៍ទី 3.6: អ្នកមើលថែរក្សា និងបុគ្គលិកក្រុមសម្របសម្រួលចាត់ចែងជួយទំនុងបំរុងលើភាសា ការចេះអាន និងសរសេរ ការចង់ចេះចង់ដឹង ការគិតគូរបែបគណិតសាស្ត្រ និងការរុករកផ្នែកវិទ្យាសាស្ត្ររបស់កុមារ។

គោលការណ៍ទី 3.7: អ្នកមើលថែរក្សា និងបុគ្គលិកក្រុមសម្របសម្រួលចាត់ចែងគាំទ្រនូវគ្រប់ទាំងពាក្យពេចន៍ឆ្លៃប្រឌិតរបស់កុមារ។

---

*សំរាប់គោលបំណងនៃ FDCQA ន័យ "កន្លែងលេងជុំគ្នា "ត្រូវបានប្រើដើម្បីរៀបរាប់ប្រាប់អំពីស្ថានការណ៍ដែលអ្នកមើលថែរក្សាពីរនាក់ (ឬច្រើនជាង) ចូលរួមគ្នាជាមួយកុមាររបស់ខ្លួនដើម្បីលេងល្បែងដែលផ្តង់លើការដកបទពិសោធន៍របស់កុមារ។ កម្មវិធីលេងអាចរៀបចំឡើងដោយអ្នកមើលថែរក្សាផ្ទាល់ ឬដោយបុគ្គលិកក្រុមសម្របសម្រួលចាត់ចែង។

## កន្លែងគុណភាពទី 4 – សុខភាព អនាម័យ ផ្នែកបំប៉នចំណីអាហារ សុវត្ថិភាព និងសុខុមាលភាព

គោលការណ៍ទី 4.1: បរិយាកាសផ្តល់សំរាប់កុមារគឺមានសុវត្ថិភាព។

គោលការណ៍ទី 4.2: ម្ហូបអាហារ និងភេសជ្ជៈមានជីវជាតិ ហើយសមរម្យទៅតាមវប្បធម៌។

គោលការណ៍ទី 4.3: សុខភាព និងនិរភ័យរបស់កុមារទាំងអស់ត្រូវបានការពារ។

គោលការណ៍ទី 4.4: ការផ្លាស់ប្តូរកន្ទប ទៅបង្គន់ និងងូតទឹកគឺជាការពិសោធន៍ល្អដាក់លាក់សំរាប់កុមារ។

គោលការណ៍ទី 4.5: សេចក្តីត្រូវការលើការសំរាក គេង និងភាពស្រណុកស្រួលរបស់កុមារត្រូវបានផ្គត់ផ្គង់។

គោលការណ៍ទី 4.6: ច្បាប់រដ្ឋ ឬដែនដីបច្ចុប្បន្នទាក់ទិននឹងផ្នែកមើលការពារកុមារ និងសុខុមាលភាពត្រូវបានអនុវត្តចាត់ចែងដោយមានភាពដូចៗគ្នា។

## កន្លែងគុណភាពទី 5 – អ្នកមើលថែរក្សា និងបុគ្គលិកក្រុមសម្របសម្រួលចាត់ចែង

គោលការណ៍ទី 5.1: ដំណើរការជ្រើសរើសបុគ្គលិកធ្វើការ ការជ្រើសរើស និងការណែនាំសំរាប់អ្នកមើលថែរក្សា និងបុគ្គលិកក្រុមសម្របសម្រួលចាត់ចែងលើកទឹកចិត្ត ហើយផ្គត់ផ្គង់ដល់ការផ្តល់នូវកិច្ចបំរើដែលមានគុណភាព។

គោលការណ៍ទី 5.2: គ្រោងការណ៍មានដំណើរការដែលធ្វើតាមគម្រោងរួចជាស្រេច ដើម្បីពិនិត្យឃ្លាំមើលការអនុវត្តបច្ចុប្បន្ន ហើយសម្គាល់មើលទីកន្លែងទាំងឡាយដើម្បីកែលំអជាបន្តបន្ទាប់ឥតដាច់។

គោលការណ៍ទី 5.3: ឱកាសអភិវឌ្ឍលើអាជីពមានផ្តល់សំរាប់អ្នកមើលថែរក្សា និងបុគ្គលិកក្រុមសម្របសម្រួលចាត់ចែង និងអ្នកឯទៀតដែលទាក់ទិននៅក្នុងការមើលគ្រប់គ្រង។

គោលការណ៍ទី 5.4: គ្រោងការណ៍ផ្សព្វផ្សាយសុខភាព និងនិរភ័យលើការងារ។

## កន្លែងគុណភាពទី 6 – ការមើលគ្រប់គ្រង និងចាត់ចែង

គោលការណ៍ទី 6.1: ការអនុវត្តរបស់អ្នកគ្រប់គ្រងគឺប្រព្រឹត្តត្រឹមត្រូវតាមសីលធម៌ ហើយចាត់ចែងស្របទៅតាមច្បាប់ដែលទាក់ទិន។

គោលការណ៍ទី 6.2: គ្រោងការណ៍ពិគ្រោះ ហើយធ្វើសហការជាមួយអ្នកចូលរួមទាំងអស់។

គោលការណ៍ទី 6.3: គ្រោងការណ៍មានដំណើរការចាត់ចែងប្រកបដោយសមត្ថភាព ប្រសិទ្ធិភាព ហើយត្រឹមត្រូវតាមសីលធម៌សំរាប់ការមើលគ្រប់គ្រងឯកសារ។

គោលការណ៍ទី 6.4: គ្រោងការណ៍មានទម្រង់ការដោះស្រាយការថ្លែងសារទុក្ខ និងការប្តឹងតវ៉ាដែលងាយស្រួល ហើយច្បាស់លាស់។

គោលការណ៍ទី 6.5: អ្នកមើលថែរក្សា និងបុគ្គលិកក្រុមសម្របសម្រួលចាត់ចែងគាំទ្រដោយប្រសិទ្ធិភាព ចំពោះកិច្ចបំរើរបស់ខ្លួននៅក្នុងសហគមន៍ ហើយស្វែងរកការសាងសង់ភ្ជាប់យ៉ាងសកម្មជាមួយភ្នាក់ងារនានាដើម្បីជាប្រយោជន៍ដល់កុមារ និងគ្រួសាររបស់គេ។

**គណៈកម្មការពិនិត្យមើលឡើងវិញលើសេចក្តីសំរេចលើការទទួលស្គាល់ជាផ្លូវការ (Accreditation Decisions Review Committee) (ADRC)**

គណៈកម្មការពិនិត្យមើលឡើងវិញ ស្តីអំពីសេចក្តីសំរេចលើការទទួលស្គាល់ជាផ្លូវការ (ADRC) ទទួលខុសត្រូវចំពោះការពិនិត្យមើលឡើងវិញនៃសេចក្តីសំរេចលើការទទួលស្គាល់ជាផ្លូវការ ធ្វើឡើងដោយ NCAC។ សមាជិកនៃ ADRC ត្រូវបានតែងតាំងឡើងដោយរដ្ឋមន្ត្រីសហព័ន្ធ ដែលទទួលបន្ទុកលើការមើលថែរក្សាកុមារ។ ADRC ចាត់ចែងកិច្ចការដោយឯករាជពី និងធ្វើការណែនាំទៅដល់ NCAC។

គ្រោងការណ៍អាចដាក់ពាក្យទៅ ADRC ដើម្បីឲ្យគេពិនិត្យមើលឡើងវិញ អំពីសេចក្តីសំរេចលើការទទួលស្គាល់ជាផ្លូវការរបស់ខ្លួន។ នៅក្នុងទស្សនៈនៃការពិនិត្យមើលសារឡើងវិញ អំពីសេចក្តីសំរេចលើការទទួលស្គាល់ជាផ្លូវការរបស់គ្រោងការណ៍ ADRC នឹងពិចារណាលើពត៌មានដែលចុះជាលាយលក្ខណ៍អក្សរ ពីគ្រោងការណ៍ដែលបញ្ជាក់ប្រាប់អំពីសេចក្តីស្នើសុំរបស់ខ្លួន ដើម្បីឲ្យមានការពិនិត្យមើលឡើងវិញនិងគ្រប់ពត៌មានទាំងអស់ដែល NCAC បានពិចារណានៅពេលធ្វើសេចក្តីសំរេចលើការទទួលស្គាល់ជាផ្លូវការរបស់ខ្លួនជាលើកដំបូង។ NCAC នឹងរាយការណ៍ប្រាប់ទៅគ្រោងការណ៍វិញជាលាយលក្ខណ៍អក្សរ អំពីសេចក្តីសំរេចចុងក្រោយរបស់ខ្លួន ហើយនឹងដាក់បញ្ចូលនូវសេចក្តីចម្លងនៃការណែនាំទាំងឡាយរបស់ ADRC ។

ពត៌មានបន្ថែមទៀតអំពី ADRC និងការស្នើសុំពិនិត្យមិលឡើងនៃសេចក្តីសំរេចលើការទទួលស្គាល់ជាផ្លូវការ គឺអាចទទួលយកបានដោយទូរស័ព្ទទៅ NCAC ឬបើកមើលគេហទំព័ររបស់ NCAC (www.ncac.gov.au)។

**ការផ្តត់ផ្តង់ប្រាក់បំណាច់មើលថែរក្សាកុមារ *(Child Care Benefit)* និងការចូលរួមជាទីពេញចិត្ត និងដំណើរការចាត់ចែងនៅក្នុង FDCQA**

ដើម្បីរក្សាសិទ្ធិទទួលយកប្រាក់បំណាច់មើលថែរក្សាកុមារ *(Child Care Benefit)* ជាបន្តបន្ទាប់ឥតដាច់ កិច្ចបំរើមើលថែរក្សាគ្រួសារនៅពេលថ្ងៃត្រូវតែអនុលោមទៅតាម *វិសោធនកម្មសំរេចចុងក្រោយ ឆ្នាំ២០០១ (លេខ១) នៃប្រាក់បំណាច់មើលថែរក្សាកុមារ (សិទ្ធិទទួលយកកិច្ចបំរើមើលថែរក្សាកុមារសំរាប់មណ្ឌលដែលមានការអនុញ្ញាតយល់ព្រម និងមណ្ឌលដែលមានការអនុញ្ញាតយល់ព្រមជាបន្តបន្ទាប់ឥតដាច់) (Child Care Benefit (Eligibility of Child Care Services for Approval and Continued Approval) Amendment Determination 2001 (No. 1)* ធ្វើឡើងនៅក្រោម ប្រព័ន្ធច្បាប់ចាត់ចែងពន្ធដារថ្មី ឆ្នាំ១៩៩៩ (ប្រាក់ជំនួយគ្រួសារ) ច្បាប់រដ្ឋបាល ឆ្នាំ១៩៩៩ *(A New Tax System (Family Assistance) Administration Act 1999*។

កិច្ចបំរើមើលថែរក្សាគ្រួសារនៅពេលថ្ងៃដែលមានការអនុញ្ញាតយល់ព្រមជាបន្តបន្ទាប់ឥតដាច់ ដែលមានសិទ្ធិទទួលយកប្រាក់បំណាច់មើលថែរក្សាកុមារ ទាក់ទិនការប្រព្រឹត្តរបស់កិច្ចបំរើទៅតាមសេចក្តីតម្រូវនៃដំណើរការចាត់ចែងជំហានទាំង៥នៃ FDCQA និងការបង្ហាញឲ្យឃើញការខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីរក្សាខ្នាតគំរូជាទីពេញចិត្តនៃការមើលថែរក្សាកុមារដែលមានគុណភាព រាប់បញ្ចូលទាំងការកែលំអគុណភាពជាបន្តបន្ទាប់ឥតដាច់ ទៅនឹងខ្នាតគំរូនៃការមើលថែទាំ ដោយអនុលោមទៅតាមកន្លែងគុណភាព និងគោលការណ៍ដូចបញ្ជាក់នៅក្នុងសៀវភៅ *Quality Practices Guide* (2004)។

ដោយអនុលោមទៅតាម*ប្រាក់បំណាច់មើលថែរក្សាកុមារ (ការបំពានលក្ខខ័ណ្ឌដែលមានការអនុញ្ញាតយល់ព្រមជាបន្តបន្ទាប់ឥតដាច់) វិសោធនកម្មសំរេចចុងក្រោយ ឆ្នាំ២០០១ (លេខ១) Child Care Benefit (Breach of Conditions for Continued Approval) Amendment Determination 2001 (No.1)* NCAC អាចរាយការណ៍ទៅក្រសួងរដ្ឋាភិបាលអូស្ត្រាលីដែលទទួលបន្ទុកលើការចាត់ចែងប្រាក់បំណាច់មើលថែរក្សាកុមារ (Child Care Benefit) អំពីកិច្ចបំរើថាគេបានធ្វេសប្រហែសដោយមិនប្រព្រឹត្តតាម ឬមិនមានដំណើរការចាត់ចែងជាទីពេញចិត្តតាមរយៈ FDCQA។

លេខាធិការនៃក្រសួង អាចដាក់ទណ្ឌកម្មកិច្ចបំរើដែលធ្វេសប្រហែសចំពោះការមិនបានបំពេញទៅលើកាតព្វកិច្ច FDCQA របស់កិច្ចបំរើ។ ទណ្ឌកម្មទាំងនេះអាចរាប់បញ្ចូលទាំងការព្យួរ ឬលុបចោលប្រាក់បំណាច់មើលថែរក្សាកុមារ (Child Care Benefit) ដែលមានការអនុញ្ញាតយល់ព្រមរបស់កិច្ចបំរើ។ កិច្ចបំរើដែលប្រាក់បំណាច់មើលថែរក្សាកុមារ (Child Care Benefit) របស់ខ្លួនត្រូវបានព្យួរ ឬលុបចោល ក៏នឹងត្រូវបាត់បង់នូវសិទ្ធិទទួលយកប្រាក់ជំនួយលើការអនុវត្ត (Operational Assistance) ផងដែរ។

**FDCQA និងច្បាប់ចេញសញ្ញាប័ត្រ**

នៅក្នុងប្រទេសអូស្ត្រាលី រដ្ឋាភិបាលប្រចាំរដ្ឋ និងដែនដីនីមួយៗ ទទួលបន្ទុកលើការចេញសញ្ញាប័ត្រឲ្យគ្រោងការណ៍មើលថែរក្សាកុមារ។ ខ្នាតគំរូជាតិសំរាប់កិច្ចបំរើមើលថែរក្សាគ្រួសារនៅពេលថ្ងៃ ត្រូវបានបង្កើតឡើងព្រមទាំងមានការយល់ព្រមដោយរដ្ឋាភិបាលសហព័ន្ធ រដ្ឋ និង ដែនដីនៅក្នុងឆ្នាំ១៩៩៧ ហើយក្រោយៗក៏ត្រូវបានកែប្រែនៅក្នុងឆ្នាំ១៩៩៩។ *ខ្នាតគំរូជាតិសំរាប់កិច្ចបំរើមើលថែរក្សាគ្រួសារនៅពេលថ្ងៃ** ត្រូវបានគ្រោងឡើងដើម្បីផ្តល់នូវដំណើរដោះស្រាយមូលដ្ឋានឯកភាពជាតិ ទៅនឹងការចេញសញ្ញាប័ត្រសំរាប់កិច្ចបំរើមើលថែរក្សាគ្រួសារនៅពេលថ្ងៃ។

នៅក្នុងរដ្ឋ និងដែនដីដែលមានច្បាប់សំរាប់ការមើលថែរក្សាគ្រួសារនៅពេលថ្ងៃការចេញសញ្ញាប័ត្រផ្តល់នូវ "សិទ្ធិ"ស្របច្បាប់ ដែលនៅពីក្រោមនេះគ្មានគ្រោងការណ៍ ឬអ្នកមើលថែរក្សាណាត្រូវបានអនុញ្ញាតឲ្យបើកធ្វើការឡើយ។ ជាធម្មតាវារាប់បញ្ចូលទាំងកត្តាមួយចំនួនដែលភាគច្រើនអាចវាស់ស្ទង់បានភ្លាមៗដូចជាទីចំហ ចំនួនគ្រឿងសម្ភារៈ ចំនួន និងអាយុរបស់កុមារ ចំនួនបុគ្គលិកធ្វើការនៅក្នុងគ្រោងការណ៍ និងរយៈពេលនៃការហ្វឹកហ្វឺនដែលគេមានសំរាប់វ័យកុមារភាព។ កត្តាទាំងនេះ*រួមចំណែក (contribute)* នៅក្នុងគុណភាព។FDCQA ពឹងផ្អែកទៅលើកត្តាទាំងនេះដើម្បីសម្លឹងទៅលើកត្តាដែល*សំរេច (determine)* ទៅលើគុណភាព។ ការផ្តង់របស់ FDCQA គឺទៅលើការអនុវត្តរបស់អ្នកមើលថែរក្សា និងបុគ្គលិក និងលទ្ធផលពិតប្រាកដសំរាប់កុមារ។ FDCQA ផ្លាស់ប្តូរការផ្តង់លើការបំពេញទៅលើខ្នាតគំរូដ៏តិចបំផុត ទៅលើការខិតខំប្រឹងប្រែងជាបន្តបន្ទាប់ឆ្ពោះទៅកាន់ការមើលថែរក្សាដែលមានកម្រិតខ្ពស់ឡើង។

ក្នុងករណីដែល NCAC ត្រូវបានរាយការណ៍អំពីការចេញសញ្ញាប័ត្រ ឬបញ្ហានៃការមើលការពារកុមារ ក្នុងទំនាក់ទំនងទៅនឹងគ្រោងការណ៍ដែលចូលរួមនៅក្នុង FDCQA ការទាក់ទងជាមួយនឹងអាជ្ញាធរសមរម្យនឹងត្រូវកើតមានឡើង។ NCAC ពិចារណាទៅលើបញ្ហាទាំង នេះ ថា បានដោះ

*នៅតាមរដ្ឋ និងដែនដីដែលពុំមានអាជ្ញាធរចេញសញ្ញាប័ត្រសំរាប់ការមើលថែរក្សាគ្រួសារនៅពេលថ្ងៃ ខ្នាតគំរូជាតិសំរាប់ការមើលថែរក្សាគ្រួសារនៅពេលថ្ងៃ ផ្តល់នូវខ្នាតគំរូជាមូលដ្ឋានសំរាប់ឲ្យកិច្ចបំរើអនុវត្ត ដើម្បីប្រាកដឲ្យបានច្បាស់លើការការពារ និងសុវត្ថិភាពនៃកុមារនៅក្នុងការមេលីថែរក្សារបស់ខ្លួន។ សូមយោងទៅលើសៀវភៅកិច្ចបំរើមើលថែទាំកុមាររបស់ក្រសួងនៃកិច្ចបំរើគ្រួសារ និងសហគមន៍(FaCS) Child Care Services Handbook(អាចទទួលយកបានតាមគេហទំព័រ FaCS នៅ www.facs.gov.au/childcare)

ស្រាយរួច ពេលណាខ្លួនបានទទួលឱវាទពីអាជ្ញាធរសមរម្យបញ្ជាក់ប្រាប់ថា ការចេញសញ្ញាប័ត្រ ឬការមើលការពារកុមារត្រូវបានដោះស្រាយរួច។ ដំណើរការចាត់ចែងទៅមុខរបស់គ្រោងការណ៍នៅក្នុង FDCQA នឹងត្រូវប៉ះពាល់ ប្រសិនបើបញ្ហានៃការចេញសញ្ញាប័ត្រ ឬការមើលការពារកុមារមិនបានដោះស្រាយរួចទេ។

## FDCQA និងការប្ដឹងតវ៉ាអំពីគ្រោងការណ៍មើលថែរក្សាគ្រួសារនៅពេលថ្ងៃដែល NCAC បានទទួល

ជាផ្នែកនៃមុខងាររបស់ខ្លួននោះ NCAC ទទួលបណ្ដឹងតវ៉ាអំពីគ្រោងការណ៍ដែលចូលរួមនៅក្នុង FDCQA។ NCAC ទទួលស្គាល់ថាការប្ដឹងតវ៉ា ឬកង្វល់ភាគច្រើនត្រូវបានគិតគូរ ហើយដោះស្រាយបានល្អប្រសើរផ្ទាល់ជាមួយគ្រោងការណ៍។ គ្រោងការណ៍ដែលចូលរួមនៅក្នុង FDCQA ត្រូវបានលើកទឹកចិត្តឲ្យបង្កើត និងរៀបចំទម្រង់ការច្បាស់លាស់ដែលឥតផ្លាស់ប្ដូរដើម្បីដោះស្រាយកង្វល់ ការទុក្ខព្រួយ ឬការប្ដឹងតវ៉ាណាមួយ។ NCAC លើកទឹកចិត្តអ្នកប្ដឹងតវ៉ាឲ្យពិភាក្សាអំពីកង្វល់របស់ខ្លួនជាមួយនឹងអ្នកមើលថែរក្សា ឬបុគ្គលិករបស់គ្រោងការណ៍។

NCAC នឹងរាយការណ៍ប្រាប់ទៅគ្រោងការណ៍អំពីបញ្ហាដែលបានលើកឡើង គឺជាការប្ដឹងតវ៉ាចុះជាលាយលក្ខណ៍អក្សរ។ ពេលណាបានទទួលពត៌មានអំពីការអនុវត្តរបស់គ្រោងការណ៍ទាក់ទិននឹងច្បាប់ចេញសញ្ញាប័ត្រក្នុងរដ្ឋ/ដែនដី ឬការមើលការពារកុមារ NCAC រាយការណ៍ទៅអាជ្ញាធរសមរម្យដែលចេញសញ្ញាប័ត្រក្នុងរដ្ឋ/ដែនដី អំពីកង្វល់ទាំងនេះ។

ការប្ដឹងតវ៉ាអំពីគ្រោងការណ៍មើលថែរក្សាគ្រួសារនៅពេលថ្ងៃត្រូវបានយល់ឃើញថាដោះស្រាយរួច ពេលណា NCAC ពេញចិត្តថាការឆ្លើយតបរបស់គ្រោងការណ៍ក្នុងទំនាក់ទំនងទៅនឹងបញ្ហានៃកង្វល់នោះ គឺគ្រប់គ្រាន់ ហើយនៅពេលណាដែលសមរម្យ ឱវាទដែលបានទទួលពីអាជ្ញាធរទាក់ទិនបញ្ជាក់ថាបញ្ហាចេញសញ្ញាប័ត្រ ឬការមើលការ ពារ កុមារត្រូវបាន ដោះស្រាយរួច។

ដំណើរការចាត់ចែងទៅមុខរបស់គ្រោងការណ៍នៅក្នុង FDCQA អាចត្រូវប៉ះពាល់ ប្រសិនបើ NCAC ពិចារណាទៅឃើញថាកង្វល់ដែលត្រូវបានលើកឡើងនៅក្នុងការប្ដឹងតវ៉ានោះមិនទាន់បានដោះស្រាយរួចទេ។

## អំពីក្រុមប្រឹក្សាជាតិទទួលស្គាល់ការមើលថែរក្សាកុមារជាផ្លូវការ (National Childcare Accreditation Council) (NCAC)

NCAC ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៣ ដើម្បីចាត់ចែងនូវប្រព័ន្ធទទួលស្គាល់ជាផ្លូវការ និងការកែលំអគុណភាព (QIAS) សំរាប់មណ្ឌលមើលថែទាំកុមារពេញមួយថ្ងៃ ពេញទូទាំងប្រទេសអូស្ត្រាលី។ នៅក្នុងឆ្នាំ២០០១ និងឆ្នាំ២០០៣ NCAC ក៏ទទួលខុសត្រូវចំពោះការចាត់ចែងប្រព័ន្ធធានាគុណភាពលើការមើលថែរក្សាគ្រួសារនៅពេលថ្ងៃ (Family Day Care Quality Assurance) (FDCQA) សំរាប់គ្រោងការណ៍មើលថែរក្សាគ្រួសារនៅពេលថ្ងៃ និងប្រព័ន្ធធានាគុណភាពលើការមើលថែទាំក្រៅម៉ោងសាលា (Outside School Hours Care Quality Assurance) (OSHCQA) សំរាប់កិច្ចបំរើមើលថែទាំក្រៅម៉ោងសាលានៅក្នុងប្រទេសអូស្ត្រាលី។ ចាប់តាំងពីបានបង្កើតមក NCAC ដើរតួនាទី និងបន្តការដើរតួនាទីជាអ្នកនាំមុខក្នុងការផ្សព្វផ្សាយ និងការកំណត់ឲ្យបានច្បាស់លាស់លើគុណភាពមើលថែរក្សាកុមារ។ NCAC ទទួលថវិកាពីរដ្ឋាភិបាលសហព័ន្ធ ហើយប្រធាន និងសមាជិក NCAC ត្រូវបានតែងតាំងឡើងដោយរដ្ឋមន្ត្រីសហព័ន្ធ ដែលទទួលបន្ទុកលើការមើលថែរក្សាកុមារ។

NCAC គឺជាអង្គការជាតិ ហើយសមាជិករបស់អង្គការនេះត្រូវបានជ្រើសរើសចេញពីរដ្ឋ និងដែនដី និងចេញពីរង្វង់អាជីពមើលថែរក្សាកុមារ និងរង្វង់អង្គការទាក់ទិនឯទៀត។

គោលបំណងរបស់ NCAC គឺដើម្បីផ្គត់ផ្គង់ និងធ្វើឲ្យបានល្អប្រសើរឡើងលើគុណភាពនៃការមើលថែរក្សា ដែលផ្ដល់នៅក្នុងកិច្ចបំរើកុមារប្រទេសអូស្ត្រាលី និងផ្ដល់ឡើងដើម្បីជួយទៅដល់អ្នកផ្ដល់ការមើលថែរក្សាកុមារ និងគ្រួសារនូវឱវាទដែលគេត្រូវការ ដើម្បីជួយឲ្យបានប្រាកដថាកុមារអូស្ត្រាលីទាំងអស់បានទទួលការមើលថែរក្សាដែលមានគុណភាពខ្ពស់។

មុខងារនៃ NCAC រាប់បញ្ចូលទាំងការទទួលស្គាល់គ្រោងការណ៍មើលថែរក្សាគ្រួសារអូស្ត្រាលីនៅពេលថ្ងៃ ដែលចូលរួមនៅក្នុង FDCQA, កិច្ចបំរើមើលថែទាំក្រៅម៉ោងសាលា អូស្ត្រាលី ដែលចូលរួមនៅក្នុង OSHCQA និងមណ្ឌលមើលថែទាំពេលថ្ងៃក្នុងរយៈពេលវែង អូស្ត្រាលី ដែលចូលរួមនៅក្នុង QIAS ហើយផ្ដល់ឱវាទទៅដល់សហព័ន្ធស្ដីអំពីការចូលរួម និងដំណើរការចាត់ចែងទៅមុខរបស់គ្រោងការណ៍មើលថែរក្សាគ្រួសារនៅពេលថ្ងៃនៅក្នុង FDCQA; កិច្ចបំរើនៅក្នុង OSHCQA; និងមណ្ឌលនៅក្នុង QIAS។

គោលបំណង និងការប្រឹងប្រែងរបស់ NCAC ទៅចំពោះអតិថិជនរបស់ខ្លួន គឺមានចុះនៅក្នុង*កិច្ចសន្យាលើកិច្ចបំរើអតិថិជន (Customer Service Charter)* ដែលអាចទទួលយកបានដោយទូរស័ព្ទទៅ NCAC ឬបើកមើលគេហទំព័ររបស់ NCAC (www.ncac.gov.au)។

## ពត៌មានច្រើនថែមទៀត

ដើម្បីទទួលយកពត៌មានបន្ថែមទៀត អំពីសញ្ញាបង្ហាញឲ្យដឹងមុនលើគុណភាព FDCQA និងខ្នាតគំរូដែលតម្រូវឲ្យមានដើម្បីឲ្យបានទទួលស្គាល់ជាផ្លូវការ សូមមើលសៀវភៅណែនាំ FDCQA *Quality Practices Guide* (2004) ឬបើកមើលគេហទំព័ររបស់ NCAC។

សៀវភៅណែនាំ FDCQA *Handbook (2004)*, FDCQA *Quality Practices Guide* (2004), FDCQA *Self-study Report* (2004) និង FDCQA *Validation Report* (2004) អាចទិញបានពី NCAC។